# ការកែទម្រង់ស្តង់ដានៃវិស័យដឹកជញ្ជូនសារធារណៈសម្រាប់ជនពិការៈ សេចក្តីសង្ខេបនៃសេចក្តីថ្លែងការណ៍ស្តីពីការពិគ្រោះយោបល់លើផលប៉ះពាល់ដល់បទបញ្ញត្តិ

## សេចក្តីផ្តើម

ប្រមាណមួយក្នុងចំណោមប្រជាជនអូស្ត្រាលីប្រាំនាក់មានពិការភាព។ មនុស្សជាច្រើនប្រើមធ្យោបាយធ្វើដំណើរសាធារណៈដើម្បីដឹកពួកគេទៅធ្វើការឬទៅរៀន ដឹកពួកគេទៅជួបគ្រួសារ មិត្តភក្តិ និងសហគមន៍ ឬ ដើម្បីទទួលសេវាកម្មនានាដូចជាការថែទាំសុខភាពជាដើម។

ស្តង់ដានៃវិស័យដឹកជញ្ជូនសាធារណៈឆ្នាំ២០០២សម្រាប់ជនពិការ (The Disability Standards for Accessible Public Transport 2002) (ហៅកាត់ថា បទដ្ឋានអំពីការដឹកជញ្ជូន (Transport Standards))ស្វែងរកមធ្យោបាយលុបបំបាត់ការរើសអើងសម្រាប់ជនពិការទាក់ទងនឹងសេវាកម្មដឹកជញ្ជូនសាធារណៈដើម្បីធ្វើឲ្យមានសមភាព និងឯករាជ្យភាព។

បទដ្ឋានអំពីការដឹកជញ្ជូនអនុវត្តចំពោះសេវាកម្មរថភ្លើង រថភ្លើងធុនស្រាល ទ្រែម (Tram)ឡានក្រុង និងឡានឆ្លងក្រុង សាឡាង តាក់ស៊ី និងអាកាសចរណ៍។ បទដ្ឋានអំពីការដឹកជញ្ជូនរចនាឡើងដើម្បីផ្តល់ភាពជាក់លាក់ដល់ជនពិការ និងអ្នកផ្តល់សេវា និងប្រតិបត្តិករសេវាកម្មដឹកជញ្ជូនសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេក្រោមច្បាប់ស្តីពីការរើសអើងជនពិការឆ្នាំ ១៩៩២ (*Disability Discrimination Act 1992* (DDA)) ។

បទដ្ឋានអំពីការដឹកជញ្ជូន តម្រូវឱ្យបណ្តាញដឹកជញ្ជូនសាធារណៈទាំងអស់របស់ប្រទេសអូស្ត្រាលី និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ មានលក្ខណៈដែលជនគ្រប់ប្រភេទអាចប្រើប្រាស់បានចាប់ពីឆ្នាំ ២០២២តទៅ (លើកលែងតែរថភ្លើង និងទ្រែម ដែលពន្យាដល់ឆ្នាំ ២០៣២តទៅ) ។

នៅខែសីហា ឆ្នាំ២០១៩ រដ្ឋមន្ត្រីដឹកជញ្ជូនទាំងឡាយរបស់ប្រទេសអូស្ត្រាលីបានយល់ព្រមធ្វើកំណែទម្រង់បទដ្ឋានអំពីការដឹកជញ្ជូនជាមួយនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន ការអភិវឌ្ឍតំបន់ និងគមនាគមន៍ ហើយនាយកដ្ឋានដឹកជញ្ជូននិងផ្លូវថ្នល់ចំបងៗ នៃរដ្ឋវិចទ័រៀជាអ្នកដឹកនាំការងារនេះ។ ការកែទម្រង់បទដ្ឋានអំពីការដឹកជញ្ជូននឹងធានាថាបទដ្ឋានទាំងនោះនៅតែមានប្រសិទ្ធិភាព បានការ ស្របតាមគោលបំណង ហើយនិងឆ្លើយតបទៅនឹងតម្រូវការ និងការរំពឹងទុករបស់សង្គមអូស្ត្រាលីនាពេលបច្ចុប្បន្ន។

បែបបទនៃការកែទម្រង់ដើម្បីជូនដំណឹងអំពីការផ្លាស់ប្តូរបទដ្ឋានដឹកជញ្ជូននាពេលអនាគតនឹងត្រូវអនុវត្តជាពីរដំណាក់កាល។ ដំណាក់កាលទី ១ របស់បែបបទនៃ ការកែទម្រង់នេះកំណត់ផ្នែកចំនួន ១៦ ដើម្បីធ្វើការកែទម្រង់ បូកបន្ថែមការធ្វើបច្ចុប្បន្នភាពលើឯកសារយោងស្តង់ដាអូស្ត្រាលីនៅក្នុងស្តង់ដាអំពីការដឹកជញ្ជូន ដោយផ្តែកលើការពិគ្រោះយោបល់ជាមួយសហគមន៍ជនពិការ រដ្ឋាភិបាលទាំងឡាយ និងឧស្សាហកម្មដឹកជញ្ជូនសាធារណៈ។

ឥឡូវនេះយើងចង់ឃើញទស្សនៈ ថាតើជម្រើសទាំងឡាយក្នុងការកែទម្រង់ដែលបានស្នើឡើង នឹងធ្វើឱ្យជនពិការអាចប្រើមធ្យោបាយដឹកជញ្ជូនសាធារណៈបានប្រសើរជាងមុន និងបទពិសោធន៍នៃសេវាកម្មដឹកជញ្ជូនសាធារណៈរបស់ប្រជាជនអូស្ត្រាលីទាំងអស់នឹងប្រសើរជាងមុ

នឬអត់។ យើងក៏ចង់បានព័ត៌មានអំពីអត្ថប្រយោជន៍ និងថ្លៃចំណាយផងដែរ ដើម្បីយើងអាចធ្វើការវិភាគចំណេញខាតសម្រាប់ដំណាក់កាលទី ១ នៃបែបបទនៃការកែទម្រង់នេះ។

## ចំណុចដែលត្រូវកែទម្រង់

យើងកំពុងតែពិចារណា ៖

- ថាតើការអភិវឌ្ឍក្របខ័ណ្ឌសម្រាប់បណ្តុះបណ្តាលបុគ្គលិកនឹងធ្វើឱ្យបទពិសោធន៍របស់ជនពិការក្នុងការប្រើសេវាដឹកជញ្ជូនសាធារណៈមានការប្រសើរឡើងឬអត់
- ថាតើត្រូវការព័ត៌មានបន្ថែមឬទេ ស្តីពីវិធានការសុវត្ថិភាពដើម្បីទប់ឧបករណ៍ដែលជាជំនួយក្នុងការធ្វើចលនាកុំឲ្យវារេនៅក្នុងឡានក្រុង រថភ្លើងជុនស្រាល និងទ្រែមក្នុងខណៈដែលយានទាំងនោះកំពុងធ្វើចលនា
- អំពីការផ្លាស់ប្តូររបៀបដែលយើងគណនាចំនួនកៅអីអាទិភាពដែលត្រូវការសម្រាប់យានយន្តដឹកជញ្ជូនសាធារណៈដើម្បីផ្តកអ្នកដំណើរដែលមានចំនួនកាន់តែច្រើនឡើងដែលត្រូវការកន្លែងអង្គុយអាទិភាពទាំងនោះ
- ថាតើត្រូវការភាពស្រឡះថែមទៀតឬអត់ដើម្បីធានាថាកន្លែងដែលបានបម្រុងទុកនឹងមិនមានឧបសគ្គ និងអាចប្រើការបាន ហើយរក្សាផ្ទាច់មុខសម្រាប់តែឧបករណ៍ដែលជាជំនួយក្នុងការធ្វើចលនា
- ថាតើធ្វើយ៉ាងណាដើម្បីធានាថាអេក្រង់ព័ត៌មានឌីជីថល និងតម្រូវការរបស់ការរចនាឆ្លើយតបទៅនឹងតម្រូវការរបស់ជនពិការ
- អំពីការធ្វើវិសោធនកម្មតម្រូវការសម្រាប់ការប្រើជណ្តើរយន្តដើម្បីឱ្យស្របទៅនឹងបទដ្ឋានឆ្នាំ២០១០ និងក្រុមសាងសង់ជាតិ ហើយនិងដើម្បីដាក់បញ្ចូលបទបញ្ញត្តិស្តីពីការថែទាំ
- អំពីការប្រកាន់យកស្តង់ដារអប្បបរិមាសម្រាប់ការចូលមើលគេហទំព័រដើម្បីកែលម្អការផ្តល់ព័ត៌មានសេវាកម្មដល់ប្រជាជនតាមរយៈប្រព័ន្ធអនឡាញ
- អំពីការបង្កើតក្របខ័ណ្ឌសម្រាប់ប្រតិបត្តិករ និងអ្នកផ្តល់សេវាដឹកជញ្ជូនសាធារណៈដើម្បីប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងក្នុងទម្រង់ផ្សេងៗគ្នាក្នុងកំឡុងពេលមានការរំខាននានាដែលបានគ្រោងទុកនិងមិនបានគ្រោងទុក
- ថាតើធ្វើយ៉ាងណាដើម្បីបញ្ជាក់ឲ្យច្បាស់ពីតម្រូវការខុសពីគេនៃទួលផ្លូវសម្រាប់ដើរចូលសាឡាង រួមទាំងផលប៉ះពាល់នៃការប្រែប្រួលកំពស់ជំនោរទឹកទៅលើលទ្ធភាពនៃការដើរចូល
- បញ្ចូលតម្រូវការក្នុងការផ្តល់កន្លែងដែលស្រួលរកសម្រាប់ឲ្យសត្វបន្ទោរបង់ នៅក្នុងឬជិតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈសំខាន់ៗ
- ការបង្កើតបទបញ្ញត្តិស្តីពីផ្លូវចេញក្នុងគ្រាអាសន្នសម្រាប់ជនពិការទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈដូចជាចំណតឡានក្រុងជាដើម
- បញ្ចូលតម្រូវការធ្វើយ៉ាងណាឲ្យជណ្តើរឬផ្លូវឡើងទួល បានជាច្រកសម្រាប់ដើរពេលចរាចរមមាញឹក និងជាច្រកចេញក្នុងគ្រាអាសន្ន ហើយធ្វើឲ្យគេមិនចង់ប្រើវាខុសយកធ្វើជាកន្លែងសម្រាប់ឈប់ទៅវិញ
- ថាតើត្រូវដោះស្រាយដោយវិធីណា ភាពមិនស៊ីចង្វាក់គ្នារវាងបទដ្ឋានដឹកជញ្ជូន និងក្រុមសាងសង់ជាតិ ដើម្បីរកផ្លូវធ្វើដំណើរឆ្ពោះទៅមុខ
- ថាតើត្រូវធ្វើឲ្យគេឃើញច្បាស់ឬអត់ អំពីឧបករណ៍បង្កប់ជាប់និងដីដែលផ្តល់សញ្ញាឲ្យដឹងទីសនៅពេលគេបើកកិនវាក្នុងបរិវេណដឹកជញ្ជូនសាធារណៈ

- ការបញ្ចូលតម្រូវការសម្រាប់ការរចនា និងការបង្កើតឲ្យមានកន្លែងសម្រាប់អ្នកដំណើរឡើងនិងចុះពីយានជំនិះ ដូចជាចំណុចទម្លាក់ចុះ / យកឡើង និងចំណតតាក់ស៊ីជាដើម
- បញ្ចូលបទបញ្ញត្តិដែលធានាឲ្យព័ត៌មានអំពីការដឹកជញ្ជូនសាធារណៈមានការផ្តល់ជូនតាមទម្រង់ជាច្រើនបែបនិងមិនមែនផ្អែកតែលើមធ្យោបាយអ៊ីនធឺណែត ប៉ុណ្ណោះទេ
- ការតម្រែតម្រង់ឯកសារយោងរបស់ស្តង់ដាអូស្ត្រាលីនៅក្នុងស្តង់ដាដឹកជញ្ជូនឲ្យត្រូវជាមួយនិងឯកសារយោងរបស់ស្តង់ដាអូស្ត្រាលីបច្ចុប្បន្ន

## សំណួរពិគ្រោះយោបល់

យើងចង់បានមតិយោបល់ និងទស្សនៈរបស់លោកអ្នកលើជម្រើសទាំងឡាយនៃការកែទម្រង់ដែលបានស្នើឡើងនេះ ដើម្បីជួយយើងខ្ញុំបង្កើតស្តង់ដាដឹកជញ្ជូនដែលមានប្រសិទ្ធភាពជាងមុនដើម្បីបង្កើនភាពងាយស្រួលក្នុងការទទួលបានសេវាកម្មនេះពីសំណាក់ប្រជាជនអូស្ត្រាលីទាំងអស់។ សូមកត់សម្គាល់ថា មានសំណួរជាក់លាក់មួយចំនួនថែងនៅក្នុងផ្នែកនីមួយៗនៃការពិគ្រោះយោបល់ RIS ។

1. តើមធ្យោបាយងាយស្រួលណាខ្លះក្នុងវិស័យដឹកជញ្ជូនសាធារណៈដែលអ្នកប្រើ?
2. តើផ្នែកណាខ្លះដែលគេអាចធ្វើឱ្យប្រសើរឡើងដើម្បីធានាថាជនពិការអាចទទួលបានសេវាដឹកជញ្ជូនសាធារណៈកាន់តែប្រសើរ?

ទាក់ទងនឹងបញ្ជីនៃកំណែទម្រង់ខាងលើ ៖

3. តើអ្នកគិតថាត្រូវមានអ្វីកើតឡើងសិនដើម្បីដោះស្រាយផ្នែកកំណែទម្រង់នីមួយៗ?
4. តើមានផ្នែកផ្សេងទៀតនៃវិស័យដឹកជញ្ជូនសាធារណៈដែលអ្នកគិតថាត្រូវមានការដោះស្រាយដែរឬទេ?
5. តើអ្នកនឹងទទួលរងផលប៉ះពាល់ដោយការផ្លាស់ប្តូរកំណែទម្រង់ដែលបានស្នើឡើងនេះយ៉ាងដូចម្តេច? តើវាជាផលប៉ះពាល់វិជ្ជមាន ឬ អវិជ្ជមាន (រួមទាំងការចំណាយហិរញ្ញវត្ថុ ឬ ចំណាយផ្សេងៗទៀត)?

## ចូរទាក់ទងយើងខ្ញុំ

លោកអ្នកអាចឆ្លើយតបដោយ៖

- បំពេញការស្ទង់មតិតាមអ៊ីនធឺណែតនៅលើគេហទំព័ររបស់យើង
- អ៊ីម៉ែលមកកាន់ DisabilityTransport@infrastructure.gov.au
- ទូរស័ព្ទមកកាន់លេខ 02 6274 6188
- សរសេរសេចក្តីស្នើ តបទៅនឹងសេចក្តីថ្លែងការណ៍ស្តីពីការពិគ្រោះយោបល់របស់យើងអំពីផលប៉ះពាល់ដល់បទបញ្ញត្តិ
- ដោយផ្ញើសេក្តីសរសេរនោះមកកាន់:

  Disability and Transport Standards Section
  COVID Freight and Logistics Branch
  Department of Infrastructure, Transport, Regional Development and Communications
  GPO Box 594
  CANBERRA ACT 2601

សម្រាប់ព័ត៌មានបន្ថែមអំពីស្តង់ដាដឹកជញ្ជូន ឬដើម្បីបំពេញការស្ទង់មតិលម្អិតបន្ថែមទៀត ឬដើម្បីទទួលបានសេចក្តីថ្លែងការណ៍ពិស្តារស្តីពីការពិគ្រោះយោបល់អំពីផលប៉ះពាល់ដល់បទបញ្ញត្តិ សូមចូលមើលគេហទំព័ររបស់យើង

www.infrastructure.gov.au/transport/disabilities